# សេវាធានារ៉ាប់រងសុខភាពអន្តរជាតិ សម្រាប់ប្រជាជនខ្មែរ និងជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា



medi+



## ភាពបត់បែន

ជាមួយ Medi+ លោកអ្នកមានភាពបត់បែនក្នុងការជ្រើសរើសគម្រោងដ៏ល្អបំផុតដែលបំពេញតាមតម្រូវការ និងសមស្របតាមថវិកាលោកអ្នក។ យើងខ្ញុំផ្តល់នូវជម្រើសគម្រោងការព្យាបាលតែនៅមន្ទីរពេទ្យ ក៏ដូចជាទាំងគម្រោងការព្យាបាលទាំងនៅមន្ទីរពេទ្យ និងការព្យាបាលជំងឺក្រៅជាមួយសេវាធានាផ្សេងៗគ្នាតាមតម្រូវការលោកអ្នក។

+ ក្នុងតំបន់ (កម្ពុជា ថៃ វៀតណាម ម៉ាឡេស៊ី)
+ តំបន់អាស៊ីអាគ្នេយ៍ (លើកលែង សិង្ហបុរី)
+ តំបន់អាស៊ីប៉ាស៊ីហ្វិក
+ អន្តរជាតិ (លើកលែង សហរដ្ឋអាមេរិក)
+ ទូទាំងពិភពលោក

ក្រៅពីជម្រើស Deductables និង Co-payment លោកអ្នកក៏អាចជាវសេវាធានារ៉ាប់រងបន្ថែមទៀតដូចជា សេវាថែទាំមាតុភាព សុខុមាលភាពសុខភាពធ្មេញ និងភ្នែកសម្រាប់គម្រោងរបស់លោកអ្នក។ ដំណោះស្រាយប្រកបដោយភាពបត់បែន ក៏ត្រូវបានរៀបចំជូនអតិថិជនដែលជាក្រុមហ៊ុនផងដែរ។

## ការធានា

Medi+ ផ្តល់នូវការធានាទូលំទូលាយសម្រាប់ការចំណាយថ្លៃព្យាបាលចាំបាច់ រួមទាំងការព្យាបាលនៅមន្ទីរពេទ្យ ការព្យាបាលជំងឺក្រៅ ទូទាំងពិភពលោក សេវាបញ្ជូនសង្គ្រោះបន្ទាន់ សុខភាពផ្លូវចិត្ត និងការធានាលើជំងឺមានស្រាប់ (សម្រាប់គម្រោងដែលជ្រើសរើស)



## សេវាកម្ម

ជាមួយ Medi+ លោកអ្នកនឹងទទួលបាននូវសេវាកម្មល្អបំផុតគ្រប់ទីកន្លែង គ្រប់ពេលវេលា។ យើងខ្ញុំនឹងជួយលោកអ្នកអំពីអត្ថប្រយោជន៍សេវាធានារ៉ាប់រង ការផ្តល់សំណង ការបញ្ជូនទៅមន្ទីរពេទ្យព្យាបាល ក៏ដូចជាសេវាកម្មអ្នកថែជំងឺផងដែរប្រសិនបើលោកអ្នកត្រូវការ។

សេវាទូរស័ព្ទបម្រើសេវាកម្ម24ម៉ោង និងបុគ្គលិកដែលមានជំនាញទំនាក់ទំនងបានច្រើនភាសារបស់យើងខ្ញុំ រង់ចាំជួយលោកអ្នក។ ក្នុងករណីសង្គ្រោះបន្ទាន់ ក្រុមពេទ្យជំនាញយើងខ្ញុំនឹងអាចផ្តល់ជូនលោកអ្នកនូវការណែនាំសង្គ្រោះបន្ទាន់ និងរៀបចំសេវាបញ្ជូនទៅសង្គ្រោះតាមយន្តហោះ ឬ ផ្លូវគោកដើម្បីបញ្ជូនលោកអ្នកទៅកាន់មន្ទីរពេទ្យប្រកបដោយគុណភាពខ្ពស់ដែលនៅជិតលោកអ្នកបំផុត។

## ភាពងាយស្រួល

Medi+ ផ្តល់នូវភាពងាយស្រួលក្នុងការទូទាត់ថ្លៃព្យាបាលដោយផ្ទាល់ជាមួយមន្ទីរពេទ្យ ដៃគូយើងខ្ញុំនៅទូទាំងពិភពលោក។ គ្រាន់តែបង្ហាញប័ណ្ណសមាជិករបស់លោកអ្នកទៅបណ្តាញមន្ទីរពេទ្យរបស់យើងខ្ញុំ នោះយើងខ្ញុំនឹងរ៉ាប់រងបង់ថ្លៃលើវិក្កយបត្រព្យាបាលជូន។

## Medi+ ផ្តល់ជូននូវ៖

+ ទឹកប្រាក់ធានារ៉ាប់រងរហូតដល់ $2,500,000 ក្នុងមួយឆ្នាំ
+ ការធានាទូលំទូលាយ
+ គម្រោងមានភាពបត់បែនតាមតម្រូវការលោកអ្នក
+ ការទូទាត់នៅតាមបណ្តាញមន្ទីរពេទ្យដៃគូយើងខ្ញុំ
+ សេវាប្រឹក្សា24ម៉ោង
+ មន្ទីរពេទ្យជាង 750,000កន្លែងទូទាំងពិភពលោក
+ ការធានាបន្តប័ណ្ណសន្យារ៉ាប់រង

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងយើងខ្ញុំតាមរយៈ
ទូរស័ព្ទលេខ 023 885 077 ឬ
mediplus@forteinsurance.com



## ក្រុមហ៊ុនធានារ៉ាប់រង ហ្វតេ (កម្ពុជា) ភីអិលស៊ី

### ការិយាល័យកណ្តាលភ្នំពេញ

អគារវឌ្ឍនៈ ជាន់ទី 18 អគារ 66 មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រលេខ 565
ទូរស័ព្ទ៖ (+855) 23 885 077 / 066 ទូរសារ៖ (+855) 23 986 922 / 882 798
អ៊ីម៉ែល៖ info@forteinsurance.com

### សាខាសៀមរាប

មណ្ឌលស្តុកចាស់ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+855) 63 963 355 ទូរសារ៖ (+855) 63 963 610
អ៊ីម៉ែល៖ srp@forteinsurance.com

### សាខាបាត់ដំបង

ផ្ទះលេខ26 ផ្លូវជាតិលេខ5 ភូមិរំចេក5 សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+855) 53 731 617 ទូរសារ៖ (+855) 53 731 700
អ៊ីម៉ែល៖ bbp@forteinsurance.com

### សាខាកំពង់ចាម

ផ្ទះលេខ8 ផ្លូវសុរាម្រិត ភូមិ3 សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+855) 42 210 167 ទូរសារ៖ (+855) 42 210 157
អ៊ីម៉ែល៖ kcp@forteinsurance.com

### សាខាព្រះសីហនុ

ផ្ទះលេខ35 ក្រុម4 សង្កាត់2 ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (+855) 34 934 955 ទូរសារ៖ (+855) 34 934 956
អ៊ីម៉ែល៖ shv@forteinsurance.com

FORTE INSURANCE

MSH